ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៩៣/១៩ - ខេន ស្ពត ស៊ូ
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ខេន ស្ពត ស៊ូ**
អាសយដ្ឋាន ៖ ភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ ៖ ០៧៨ ៧៧៧ ៦១៩ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក សុះ មើ | ប្រធានរដ្ឋបាល |
| ២- លោក ឡាច សារុន | ទីប្រឹក្សាក្រុមហ៊ុន |
| ៣- លោក អ៊ុក អ៊ិន | បុគ្គលិករដ្ឋបាល |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ខេន ស្ពត ស៊ូ**
អាសយដ្ឋាន ៖ ភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ ៖ ០៨១ ៨៨៧ ៧០១/០៨១ ៤៧៨ ០១៥ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក ឈេន សំបូរ | មេធាវី |
| ២- លោកស្រី ម៉ន ចន្ធា | មន្ត្រីសហព័ន្ធសហជីពកម្ពុជា |
| ៣- លោកស្រី រិន សេរី | ប្រធានសហជីពកម្ពុជា(មូលដ្ឋាន) |



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh◆ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org◆ Website: www.arbitrationcouncil.org

៤- លោកស្រី ហែន បុប្ផា ហិរញ្ញិកសហជីពកម្ពុជា(មូលដ្ឋាន)

៥- លោកស្រី ប៉ែន សុភ័ន ប្រធានសហជីពយុវជនខ្មែរ(មូលដ្ឋាន)

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែស្នើសុំឱ្យក្រុមហ៊ុនបើកច្រកចេញចូលអគារ ទ៣ ជាបន្ទាន់។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី ១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ពត ស៊ូ លេខ ១១៤៧ ក.ប/កធ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០១៩។

## សវនាការ និង សន្ទេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃចន្ទ ១រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានទទួលពាក្យបណ្តឹងរបស់ភាគីកម្មករនិយោជិត ស្តីពីការស្នើសុំជួយដោះស្រាយនូវលក្ខខណ្ឌការងារចំនួន ២ ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានចាត់មន្ត្រីជំនាញឱ្យដោះស្រាយវិវាទការងារនេះតាមនីតិវិធីច្បាប់ និងផ្សះផ្សា នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០១៩ ដោយទទួលបានលទ្ធផលសះជានឹងគ្នា ១ ចំណុច។ ចំណុចមិនសះជាដែលនៅសល់ចំនួន ១ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៩ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ពត ស៊ូ ខូអិលធីឌី លេខ ១១៤៧ កប/កធ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និង

ផ្សះផ្សាលើករណីមិនសះជាចំនួន ១ ចំណុច នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក។ នៅថ្ងៃសវនាការ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារភស្តុតាង និងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារភស្តុតាង។

ភាគីទាំងពីរឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៩ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

ក្រុមអាជ្ញាកណ្តាលបានចុះត្រួតពិនិត្យដល់ទីតាំងក្រុមហ៊ុន ខេត ស្ពត ស៊ូ ខូអិលធីឌី នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- ប័ណ្ណប៉ាតង់ឆ្នាំ២០១៩ ក្រុមហ៊ុន ខេន ស្ពត ស៊ូ លេខ PTL 2019021459 អពជ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩។

២- វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ-សិប្បកម្ម ក្រុមហ៊ុន ខេន ស្ពត ស៊ូ លេខ ៦៨២៣ ឧសក ឧវប១២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

៣- ប្រកាសបង្កើតរោងចក្រ ខេន ស្ពត ស៊ូ លេខ ៦២៥ឧសកឧប្រក១២ ចុះថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧

៤- លិខិតផ្ទេរសិទ្ធិរបស់លោក ស្តេឡា ចាង ជានាយកប្រតិបត្តិក្រុមហ៊ុន ខេន ស្ពត ស៊ូ ខូអិលធីឌី ផ្ទេរសិទ្ធិជូនលោក សុះ មើ លោក ឡាច សារុន និងលោក អ៊ុក អ៊ុន ចុះថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ខេន ស្ពត ស៊ូ ចុះទិដ្ឋាការ លេខ ៥១១ ក.ប/ក.ឆ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ដោយមន្ទីរការងារខេត្តកំពង់ឆ្នាំង។

៦- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ខេន ស្ពត ស៊ូ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ ២០១៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតតំណាងដោយអណត្តិរបស់លោកមេធាវី ឈេន សំបូរ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីតំណាងដោយអាណត្តិអោយអាណត្តិទាយក ឈ្មោះ រិន សេរី និងឈ្មោះ ហ៊ែន ម្នាស ចុះថ្ងៃសុក្រ ៥រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩។

២- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់អាណត្តិទាយកឈ្មោះ រិន សេរី និងឈ្មោះ ហែន បុផ្ផា ប្រគល់សិទ្ធិជូនលោកមេធាវី ឈេន សំបូរ ចុះថ្ងៃសុក្រ ៥រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩។

៣- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពកម្ពុជា នៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ១៣៧៣ កប/កធ ចុះថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០១៧។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥៣៨ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ១០កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

៥- សារណាការពារ របស់មេធាវី ឈេន សំបូរ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាការពារឱ្យអាណត្តិទាយកឈ្មោះ រិន សេរី, ឈ្មោះ ប៉ែន សុភ័ន និងឈ្មោះ ហែន បុផ្ផា ចុះថ្ងៃសុក្រ ៥រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩។

៦- សារណាការពារបន្ថែម របស់មេធាវី ឈេន សំបូរ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាការពារឱ្យអាណត្តិទាយកឈ្មោះ រិន សេរី, ឈ្មោះ ប៉ែន សុភ័ន និងឈ្មោះ ហែន បុផ្ផា ចុះថ្ងៃសុក្រ ១២រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១៩។

៧- ឯកសារអត្តលេខកម្មការនីពោះធំនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ខូអិលធីឌី។

៨- ឯកសារអត្តលេខកម្មករជនពិការនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ខូអិលធីឌី។

៩- ឯកសារជារូបភាព។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ១១៤៧ ក.ប/កធ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ០០៩/១៩ ក.ប/ក.ធ.ល.ប.រ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៥៣៧ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ១០កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥៣៨ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ១០កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៥៤៩ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ១៣ កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥៥០ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ១៣កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

ក្រុមហ៊ុនខេន ស្ពត ស៊ូ ខូអិលធីឌី (ដែលតទៅនេះហៅថា ក្រុមហ៊ុន ខេន ស្ពត ស៊ូ) គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងផ្នែកផលិតស្បែកជើង និងមានជួលកម្មករនិយោជិត សរុបចំនួន ៩៩៥៥ នាក់ (យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុនខេន ស្ពត ស៊ូ ខូអិលធីឌី)។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិត ទាមទារឱ្យនិយោជកបើកច្រកចេញចូលអគារ S3 ជាបន្ទាន់**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកបើកច្រកចេញចូលនៃអគារ S3 នៅពេលកម្មករនិយោជិតចូលធ្វើការនិងចេញពីធ្វើការ។
- ភាគីទាំងពីរទទួលស្គាល់ថា៖
  - អាគារ S3 បានបើកដំណើរការនៅខែឧសភា ឆ្នាំ២០១៩ ដោយមានកម្មករនិយោជិតធ្វើការចំនួនប្រហែល ១៦០០ នាក់។ អាគារនេះ មានច្រកទ្វារមួយ ហើយនិយោជកមិនបានបើកទ្វារនេះ ឱ្យកម្មករនិយោជិតចេញ-ចូល ទេ។ ប៉ុន្តែ សម្រាប់ពេលរសៀល ម៉ោងចេញពីធ្វើការ និយោជកបានសម្រួលបើកច្រកនេះ ឱ្យកម្មករនិយោជិតចេញត្រឡប់ទៅផ្ទះវិញ។ និយោជកមិនបើកទ្វារនេះប្រើប្រាស់ គឺដើម្បីបង្ការការកកស្ទះចរាចរណ៍ ដោយសារជារៀងរាល់ព្រឹក មានរថយន្តដឹកជញ្ជូនកម្មករនិយោជិត ចំនួនប្រហែល ១៧០ ធ្វើដំណើរចូលក្រុមហ៊ុន។
  - ម៉ោងធ្វើការ គឺចាប់ផ្តើមពីម៉ោង ៧ ព្រឹក ហើយនិយោជកបើកច្រកទ្វារធំឱ្យកម្មករនិយោជិតចូលនៅម៉ោង៦ និង៣៥ នាទីព្រឹក។
  - ចំពោះកម្មករនិយោជិតដែលជាស្ត្រីមានផ្ទៃពោះ និងជនពិការ និយោជកបានសម្រួលឱ្យគាត់ចេញពីធ្វើការមុនម៉ោងរយៈពេល ១៥នាទី។
- កម្មករនិយោជិតនៃអគារ S3 ត្រូវធ្វើដំណើរថ្មើរជើង ពីចំណតរថយន្ត ឬច្រកទ្វារធំ ទៅអាគារ S3 ដែលមានចម្ងាយចន្លោះពី ៥០០ ទៅ ៨០០ ម៉ែត្រ។ ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារ ថា៖
  - កម្មករនិយោជិតត្រូវចំណាយពេលធ្វើដំណើរថ្មើរជើងរយៈពេល ១០ នាទី សម្រាប់មនុស្សប្រុស ១៥នាទី សម្រាប់មនុស្សស្រី និង២០ នាទី សម្រាប់ស្ត្រីមានផ្ទៃពោះ និងជនពិការ។
  - និយោជក កម្មករនិយោជិត ត្រូវធ្វើដំណើរថ្មើរជើងទៅអគារ S3 មានចម្ងាយឆ្ងាយ ធ្វើឱ្យកម្មករនិយោជិតឆូតកាតមិនទាន់ ផុតម៉ោងចូលធ្វើការ ។ ប្រសិនបើកម្មករនិយោជិតណាទៅយឺត ត្រូវ

បានប្រធានក្រុមចិនព្រមានឱ្យឈរនៅខាងក្រៅ និងស្តីបន្ទោស។ ដែលធ្លាប់កើតឡើងនៅក្នុងខែកញ្ញា ឆ្នាំ២០១៩ លើកម្មករនិយោជិតឈ្មោះ ឃុំ ប៉ាលី (ហៅ ក្រញាញ់) មកយឺតត្រូវបានប្រធានក្រុមចិនព្រមានឱ្យឈរនៅខាងក្រៅ និងស្តីបន្ទោសនៅមុខកម្មករដ៏ទៃទៀត។

- កម្មករនិយោជិត ដែលធ្វើការនៅអគារ S3 មានចំនួន ១៦០០ នាក់ ដែលក្នុងនោះមានកម្មការនីមានផ្ទៃពោះប្រហែល ២០នាក់ និងជនពិការប្រហែល ៣នាក់។
- ច្រកចូលអគារមានតែមួយ តូចចង្អៀត ពេលកម្មករនិយោជិតចូលអគារ S3 ប្រជ្រៀតគ្នា បើមានអគ្គិភ័យកើតឡើង កម្មករនិយោជិតអាចមានគ្រោះថ្នាក់ ព្រោះបរិវេណក្រុមហ៊ុនអត់មានច្រកសុវត្ថិភាពរត់ចេញទេ។ កន្លងមកធ្លាប់មានកម្មករនិយោជិតគ្រោះថ្នាក់ក្នុងខែកក្កដា ឆ្នាំ ២០១៩ កម្មការនីដួលរលូតកូន និងក្នុងខែសីហា ឆ្នាំ២០១៩ កម្មករនិយោជិតដួលរបួសជើង។
- និយោជកធ្វើបែបនេះ ផ្ទុយពីវិធានសុខសុវត្ថិភាពរបស់កម្មករនិយោជិត មាត្រា ២២៩ នៃច្បាប់ស្តីពីការងារ ចែងថា "*គ្រប់គ្រឹស្ថាន និងទីកន្លែងធ្វើការ ត្រូវរក្សាឱ្យបានស្អាត ហើយបង្ហាញថាមានលក្ខខ័ណ្ឌអនាម័យ និងសភាពសុខសប្បាយជានិច្ច ឬទូទៅ ត្រូវឱ្យមានលក្ខខ័ណ្ឌការងារចាំបាច់សំរាប់សុខភាពរបស់កម្មករនិយោជិត*"។ និយោជកគួរតែបើកច្រកចេញចូលអគារ S3 ដើម្បីបង្ការការកកស្ទះបណ្តាលឱ្យយឺតម៉ោងការងារ និងហានិភ័យផ្សេងៗ។

- ភាគីនិយោជកមិនអាចបើកច្រកចេញចូលអគារ S3 តាមការទាមទាររបស់កម្មករនិយោជិតទេ ដោយសារៈ
  - នៅខាងមុខអគារ S3 មានច្រកចេញចូលមួយនៅជាប់ផ្លូវ ប៉ុន្តែនៅពេលព្រឹកមិនអាចបើកឱ្យកម្មករនិយោជិតចូលបានទេ ព្រោះនៅមុនអគារ S3 មិនមានចំណតរថយន្ត។ឡានដឹកកម្មករនិយោជិតចំនួន ១៧០គ្រឿង និងកម្មករនិយោជិតដែលធ្វើការនៅអគារ S3 ចំនួន១៦០០នាក់ ប្រសិនបើឈប់ឡានដាក់កម្មករនិយោជិតចុះនៅមុខច្រកចេញចូលអគារ S3 បណ្តាលឱ្យកកស្ទះចរាចរណ៍។
  - និយោជកទើបតែដួលអគារថ្មីកំពុងតែរៀបចំ ហើយនិយោជកកំពុងព្យាយាមដោះស្រាយ ធ្វើយ៉ាងណាសម្រួលដល់កម្មករនិយោជិតឱ្យបានស្រួល។
  - និយោជកបានសម្រួលដាក់ម៉ាស៊ីនឆូតកាតនៅជិតចំណតរថយន្តចំនួន ២ ទៅ ៣ គ្រឿង សម្រាប់ឱ្យកម្មករនិយោជិតដែលមកយឺតម៉ោងអាចឆូតកាតបាន ឬមកឆូតកាតនៅអគារ S3 បាន។
  - ជាគោលការណ៍ ចំពោះករណីដែលថាកម្មករនិយោជិតមកយឺត មិនមានការព្រមានឱ្យកម្មករនិយោជិតឈរនៅខាងក្រៅនិងស្តីបន្ទោសទេ។ ជាធម្មតា នៅពេលដល់ម៉ោងចូលធ្វើការមិនមែនចូលភ្លាមទេ គឺត្រូវប្រជុំតាមក្រុមណែនាំអំពីវិន័យ ហើយកម្មករនិយោជិត ដែលបើអ្នកណាប្រធានក្រុមគ្រាន់តែណែនាំមិនមែនព្រមាន ឬទណ្ឌកម្មទេ។
  - ក្នុងបរិវេណក្រុមហ៊ុន មានច្រកសុវត្ថិភាព និងស្លាកសញ្ញា។ លើសពីនេះ និយោជកមានការបង្រៀនរបៀបរត់តាមច្រកសុវត្ថិភាព និងបង្ហាញស្លាកសញ្ញា ដើម្បីការពារករណីអគ្គិភ័យកើតឡើងដល់កម្មករនិយោជិតក្នុងមួយឆ្នាំ ២ដង។

ARBITRATION COUNCIL

- ក្រុមអាជ្ញាកណ្តាលបានចុះត្រួតពិនិត្យដល់ទីតាំងក្រុមហ៊ុន ខេត ស្ពត ស៊ូ ខូអិលធីឌី នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ បានរកឃើញថា៖
    - នៅខាងមុខអគារ S3 មិនមានចំណតរថយន្ត និងកន្លែងឱ្យកម្មករនិយោជិតឈរចាំទេ។
    - នៅពេលព្រឹក មានរថយន្តជូនកម្មករនិយោជិតចូលក្នុងក្រុមហ៊ុនច្រើន ដែលអាចបណ្តាលឱ្យកកស្ទះចរាចរណ៍។
    - នៅមុនពេលចូលធ្វើការនៅតាមក្រុមនីមួយៗ ប្រជុំណែនាំអំពីវិន័យជាមុន។
    - ច្រកចូលទៅអគារ S3 និយោជកកំពុងរៀបចំឱ្យធំទូលាយ ហើយច្រកចូលនេះ មិនតូចចង្អៀតដែលបណ្តាលឱ្យកកស្ទះនោះទេ។

ភាគីកម្មករនិយោជិតបានដាក់ភស្តុតាងបញ្ជាក់ដូចខាងក្រោម៖

- កម្មករនិយោជិត ឈ្មោះ នាង វ័ន្ត អត្តលេខP000៧0 ត្រូវរបួសដោយសារដួល និងបុកទ្វារនៅពេលពួកគេសម្រុកប្រជ្រៀតគ្នាចូលទៅអគារ S3។
- កម្មការនីឈ្មោះ យ៉ង់ ផុន អត្តលេខ P១៣៩៣ បានរអិលជើងរលូតកូន ពេលដើរប្រញាប់ចូលទៅធ្វើការ។
- កម្មករនិយោជិតឈ្មោះ លាត ចាន់ណា អត្តលេខ P0២៤៦៧ ត្រូវបានប្រធានផ្នែកចិនព្រមានស្តីបន្ទោស និងដាក់ទណ្ឌកម្មឱ្យឈរហាលថ្ងៃ។
- កម្មការនីមានផ្ទៃពោះនៃអគារ S3 មានចំនួន ៣២ នាក់ និងជនពិការមានចំនួន ៨នាក់។

## ហេតុផលនៃសេចក្តីសម្រេច ៖

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកបើកច្រកចេញចូលអគារ S3 នៅពេលកម្មករនិយោជិតចូលធ្វើការនិងចេញពីធ្វើការ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចបើកច្រកចេញចូលអគារ S3 នៅពេលកម្មករនិយោជិតចូលធ្វើការនិងចេញពីធ្វើការ ជូនកម្មករនិយោជិត ដែរឬទេ?

កថាខណ្ឌ ២ មាត្រា ២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា *"...សហគ្រាសនីមួយៗអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះ មានប្រើមនុស្សមួយក្រុម ធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន។ល។ ក្រោមការគ្រប់គ្រង និង ដឹកនាំនៃនិយោជក..."*។

តាមរយៈកថាខណ្ឌ ២ មាត្រា ២ នៃច្បាប់ស្តីពីការងារខាងលើ មានន័យថា និយោជកមានសិទ្ធិចាត់ចែងនិងគ្រប់គ្រងក្រុមហ៊ុន ដរាបណាសិទ្ធិនេះត្រូវបានធ្វើឡើងដោយស្របច្បាប់ និងសមហេតុផល។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ៦២/០៦-ឃ្វីកស៊ូ ហេតុផលនៃចំណុចវិវាទទី៥, លេខ ១០៨/០៦-ទ្រីនុងហ្គាល កូម៉ាក់, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៣, ៣៩/០៩-ឃ្វីនធ័ មេជើរ ហេតុផលចំណុចវិវាទទី២, លេខ ១១៩/០៩-អេស អិល ហេតុផលនៃចំណុចវិវាទទី៤ និងទី៥ និងលេខ ០២៩/១៥-ប្រ៊ីជីស អឹមើរខិន ចឺប៊ែកខូ ខេមបូឌា ហេតុផលនៃចំណុចវិវាទទី៣ ទី៤ និងទី៥)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើនេះដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការចាត់ចែងរបស់និយោជក ឱ្យកម្មករនិយោជិតធ្វើដំណើរថ្មើរជើង ពីចំណតរថយន្ត ឬច្រកទ្វារធំទៅអគារ S3 ត្រឹមត្រូវតាមច្បាប់ និងសមហេតុផល ដែរឬទេ?

*កថាខណ្ឌទី១ មាត្រា ២៤៨ នៃច្បាប់ស្តីពីការងារ បានចែងថា ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសមកពីកម្មករនិយោជិត ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈ មានឈ្នួលក្តីឥតឈ្នួលក្តី កាន់មុខងារជាអ្វី នៅទីកន្លែងណាក៏ដោយ។”។*

កថាខណ្ឌទី១ មាត្រា ២៤៩ នៃច្បាប់ស្តីពីការងារខាងលើ បានចែងថា *“នាយកសហគ្រាស ត្រូវទទួលខុសត្រូវលើគ្រោះថ្នាក់ការងារទាំងអស់ដូចមានរៀបរាប់ក្នុងមាត្រាខាងលើនេះ ទោះបីលក្ខន្តិកៈផ្ទាល់ខ្លួនរបស់កម្មករនិយោជិតម្នាក់ៗនោះមានលក្ខណៈយ៉ាងណាក៏ដោយ”*។

មាត្រា ២៥០ នៃច្បាប់ស្តីពីការងារខាងលើ បានចែងថា *“នាយកសហគ្រាសគ្រប់រូបត្រូវចាត់ ឬប្រើឱ្យគេចាត់វិធានការចាំបាច់ទាំងអស់ដើម្បីបង្ការគ្រោះថ្នាក់ការងារផ្សេងៗ”*។

យោងតាមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៩៤/០៤-ក្រុមហ៊ុនកាត់ដេរ អ៊ីចឹនីជី អាកែវីល ហេតុផលនៃចំណុចវិវាទទី៥ បានបកស្រាយមាត្រា ២៤៩ និងមាត្រា ២៥០ នៃច្បាប់ស្តីពីការងារខាងលើថា *“យោងតាមមាត្រានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នាយកសហគ្រាសមានសិទ្ធិដើម្បីដាក់វិធានការចាំបាច់ និងមានសិទ្ធិរៀបចំការគ្រប់គ្រងសហគ្រាសរបស់ខ្លួនឱ្យមានសណ្តាប់ធ្នាប់ ដើម្បីការពារកុំឱ្យមានគ្រោះថ្នាក់ការងារដល់កម្មករនិយោជិតក្នុងសហគ្រាស”*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើនេះដែរ។ យោងតាមកថាខណ្ឌទី១ មាត្រា ២៤៩ និងមាត្រា ២៥០ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌការងារចាំបាច់សម្រាប់សុខភាពរបស់កម្មករនិយោជិត និងវិធានការចាំបាច់ទាំងអស់ដើម្បីបង្ការគ្រោះថ្នាក់ការងារផ្សេងៗ គឺជាកាតព្វកិច្ចរបស់និយោជកដែលត្រូវទទួលខុសត្រូវ។

យោងតាមអង្គហេតុ និងការពិនិត្យរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការចាត់ចែងរបស់និយោជកដែលតម្រូវឱ្យរថយន្តដូនកម្មករនិយោជិតទាំងអស់ទៅឈប់នៅចំណត និងឱ្យកម្មករនិយោជិតដើរទៅកាន់អាគារធ្វើការតាមច្រកក្បែរចំណតរថយន្ត ហាក់មានភាពសមហេតុផល និងធ្វើឱ្យមានសណ្តាប់ធ្នាប់នៅក្នុងក្រុមហ៊ុន។ លើសពីនេះ វាអាចជួយបញ្ចៀសការស្ទះចរាចរណ៍នៅមុខក្រុមហ៊ុន ដែលអាចបណ្តាលឱ្យកម្មករនិយោជិតមកធ្វើការយឺតផងដែរ។ ម្យ៉ាងទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការដើរពីចំណតរថយន្តទៅអគារ S3 ចម្ងាយប្រហែលពី ៥០០ ទៅ ៨០០ ម៉ែត្រ មិនអាចបង្កឱ្យប៉ះពាល់សុខភាព ឬមានគ្រោះថ្នាក់ការងារ និងហានិភ័យផ្សេងៗដល់កម្មករនិយោជិតទូទៅទេ។ ប៉ុន្តែសម្រាប់កម្មការនីមានផ្ទៃពោះ និងជនពិការ ការចាត់ចែងនេះអាចនឹងប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពរបស់ពួកគាត់។ ជាក់ស្តែង គឺករណីរបស់កម្មករនិយោជិត យ៉ង់ ផុន ដែលបានរអិលជើងរលូតកូន ពេលប្រញាប់ដើរចូលទៅធ្វើការ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្នុងចំណោមកម្មករនិយោជិតចំនួន ១៦០០ នាក់ ដែលកំពុងបម្រើការងារនៅក្នុងអាគារ S3 មានកម្មករនិយោជិតដែលជាស្ត្រីមានផ្ទៃពោះចំនួន ៣២ នាក់ និងជនពិការមានចំនួន ៨នាក់ ប៉ុន្តែនិយោជកមិនបានផ្តល់មធ្យោបាយណាមួយដើម្បីសម្រួលដល់ការធ្វើដំណើររបស់ពួកគាត់ពីច្រកទ្វារធំទៅអាគារ S3 នោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការចាត់ចែងរបស់និយោជកដែលតម្រូវឱ្យកម្មករនិយោជិតដែលជាស្ត្រីមានផ្ទៃពោះ និងជនពិការដើរពីចំណតរថយន្ត

THE ARBITRATION COUNCIL

ទៅអាគារ S3 គឺមិនសមហេតុផល និងស្របតាមមាត្រា ២៤៨ ដល់មាត្រា ២៥០ នៃច្បាប់ស្តីពីការងារ ខាងលើនោះទេ។

ផ្អែកតាមការចុះអង្កេតស្ថានភាពជាក់ស្តែងនៅក្នុងក្រុមហ៊ុន ខេន ស្ព័ត ស៊ូ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅតាមផ្លូវប្រេបបងនៃអាគារ S3 មានទីធ្លាគ្រប់គ្រាន់ឱ្យរថយន្តឈប់សម្រាប់ឱ្យកម្មករនិយោជិតដែលជាស្ត្រីមានផ្ទៃពោះ និងជនពិការអាចចុះបាន។ ហេតុនេះ និយោជកគួរគប្បីសម្រួលដល់កម្មករនិយោជិតដែលជាស្ត្រីមានផ្ទៃពោះ និងជនពិការ ដោយឱ្យរថយន្តជូនកម្មករនិយោជិតចូលដល់ចំណតរថយន្តសិន ដើម្បីឱ្យកម្មករនិយោជិតដទៃចុះ រួចចាំបត់ត្រឡប់មកអាគារ S3 វិញ ឱ្យកម្មករនិយោជិតដែលជាស្ត្រីមានផ្ទៃពោះ និងជនពិការ ចុះនិងចូលតាមច្រកចេញចូលនៃអគារ S3។ ការអនុវត្តនេះអាចធ្វើទៅបានពីព្រោះចំនួនកម្មករនិយោជិតដែលជាស្ត្រីមានផ្ទៃពោះនិងជនពិការ មានតិចនិងមិនបង្កឱ្យមានការកកស្ទះចរាចរណ៍ទេ។

ចំពោះករណីចេញពីធ្វើការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកបានអនុញ្ញាតឱ្យកម្មករនិយោជិតដែលជាស្ត្រីមានផ្ទៃពោះ និងជនពិការ ចេញមុនម៉ោង ១៥នាទី រួចហើយ។ ហេតុនេះ ពួកគាត់មិនមានផលលំបាកក្នុងការប្រញាប់ ឬប្រជ្រៀតជាមួយនឹងកម្មករនិយោជិតផ្សេងទៀត ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់គាត់នោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអនុវត្តនេះ គឺសមហេតុផល និងស្របច្បាប់ហើយ។ មួយវិញទៀត ចំពោះករណីកម្មករនិយោជិតមកដល់អគារ S3 យឺតបន្តិចបន្តួចដោយសារធ្វើដំណើរឆ្ងាយ និយោជកបានអះអាងថា និយោជកនឹងមិនព្រមានពួកគាត់នោះទេ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចបើកច្រកចេញចូលអគារ S3 ពេលចូលធ្វើការ និងចេញពីធ្វើការ ជូនកម្មករនិយោជិតទេ ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច៖

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបើកច្រកចេញចូលអគារ S3 នៅពេលកម្មករនិយោជិតចូលធ្វើការ និងចេញពីធ្វើការជូនកម្មករនិយោជិត។
- បង្គាប់ឱ្យនិយោជកបើកច្រកចេញចូលអគារ S3 សម្រាប់កម្មករនិយោជិតដែលជាស្ត្រីមានផ្ទៃពោះ និងជនពិការ ចូលក្នុងអាគារ S3 ពេលចូលធ្វើការ ឬដឹកជញ្ជូនស្ត្រីមានផ្ទៃពោះ និងជនពិការពីចំណតរថយន្តរួមទៅអាគារ S3 ពេលចូលធ្វើការ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបើកច្រកចេញចូលអគារ S3 នៅពេលកម្មករនិយោជិតចូលធ្វើការ និងចេញពីធ្វើការជូនកម្មករនិយោជិត លើកលែងកម្មករនិយោជិតដែលជាស្ត្រីមានផ្ទៃពោះ និងជនពិការ ។
- បង្គាប់ឱ្យនិយោជកបើកច្រកចេញចូលអគារ S3 សម្រាប់កម្មករនិយោជិតដែលជាស្ត្រីមានផ្ទៃពោះ និងជនពិការ ចូលក្នុងអាគារ S3 ពេលចូលធ្វើការ ឬដឹកជញ្ជូនស្ត្រីមានផ្ទៃពោះ និងជនពិការពីចំណតរថយន្តរួមទៅអាគារ S3 ពេលចូលធ្វើការ។

THE ARBITRATION COUNCIL

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹម សុទ្ធី**

ហត្ថលេខា ៖ ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីម សុវណ្ណា**

ហត្ថលេខា ៖------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------------

ARBITRATION COUNCIL